ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :...៣៦៤/២០...ក.ប/ប្រក.ក.ប.ក

ក្រសួងពាណិជ្ជកម្ម

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការអនុវត្តគម្រោងពេចក្រកាន់តែប្រសើរនៅកម្ពុជាលើវិស័យនាំចេញវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និង ផលិតផលធ្វើដំណើរនិងកាបូប

**រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ២៣២ ព.ណាបអព.ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទចុះបញ្ជីទទួលសិទ្ធិនាំចេញទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- យោងសារាចរណែនាំលេខ ០៦. សរណន ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការអនុវត្តគំរោងរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់
- យោងអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការអន្តរជាតិខាងការងារ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងជំរុញឲ្យរោងចក្រ សហគ្រាស ព្រមទាំងការិយភារីនៃផ្នែកវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងរោងចក្រ សហគ្រាសផលិតផលិតផលធ្វើដំណើរនិងកាបូប ចូលជាសមាជិកគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ដើម្បីចូលរួមចំណែកកសាងសេដ្ឋកិច្ចនិងលើកកម្ពស់ការប្រកួតប្រជែងរបស់កម្ពុជាតាមរយៈការវាយតម្លៃការអនុវត្តលក្ខខណ្ឌការងារនៅក្នុងរោងចក្រ សហគ្រាសទាំងនោះ ដោយផ្អែកលើច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបសន្តិសុខសង្គម និងបទដ្ឋានការងារស្នូលដែលបានទទួលស្គាល់ជាអន្តរជាតិ។

**ប្រការ២ .-**

រោងចក្រ សហគ្រាស ព្រមទាំងការិយភារីនៃផ្នែកវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់ និង រោងចក្រ សហគ្រាសផលិតផលិតផលធ្វើដំណើរនិងកាបូប ត្រូវបង់វិភាគទានហិរញ្ញវត្ថុទ្រទ្រង់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាតាមរយៈសមាគមរោងចក្រកាត់ដេរនៅកម្ពុជាទើបមានសិទ្ធិចូលជាសមាជិកគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។

**ប្រការ៣ .-**

រោងចក្រ សហគ្រាស ព្រមទាំងការិយភារីនៃផ្នែកវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់ និង រោងចក្រ សហគ្រាសផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលបានចុះបញ្ជីជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ទើបអាចស្នើសុំចុះបញ្ជីទទួលសិទ្ធិនាំចេញទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ស្របតាមប្រកាសលេខ២៣២ ព.ណបអព.ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទចុះបញ្ជីទទួលសិទ្ធិនាំចេញទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

**ប្រការ៤ .-**

ប្រកាសលេខ១០៨ ក.ព.ណ/ម ២០០១ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០១ ស្តីពីការអនុវត្តគម្រោងត្រួតពិនិត្យការងាររបស់អង្គការអន្តរជាតិខាងការងារនៅក្នុងវិស័យនាំចេញវាយនភណ្ឌនិងសម្លៀកបំពាក់កម្ពុជា

ទៅទីផ្សារសហរដ្ឋអាមេរិកនិងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធាននាយកដ្ឋានពេទ្យការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធាននាយកដ្ឋាននាំចេញ-នាំចូល ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល**:
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
  ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ក្រសួង ស្ថាប័នពាក់ព័ន្ធ
- -ដូចប្រការ៥
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ